ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៥០៣
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧
សំណុំរឿងជំនុំជម្រះ
លេខ៖២០១៧
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌ
លេខ:៤៧៣ “ឃ” ក្រ១០
ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧

## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៧ វេលាម៉ោង ០២ :៣០ រសៀល ដែលមានសមាសភាពជំនុំជម្រះដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥០៣ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ ៖

- ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ១៥ ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើត រាជធានីភ្នំពេញ ទីលំនៅមុខពេលឃាត់ខ្លួនផ្ទះលេខ១៤៣ ផ្លូវលំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារ ម២ (ព្រៃសនៃក្រសួងមហាផ្ទៃ ) ឪពុកឈ្មោ[redacted] “រស់” ម្តាយឈ្មោ[redacted] រស់” នៅលើវ ជានីតិជន ទោសពីមុនគ្មាន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៥៨៤ ដ.ឃ.ង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ ។

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

### អង្គហេតុ

កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ កម្លាំងសមត្ថកិច្ចនៃមន្ទីរប្រឆាំងគ្រឿងញៀនបានអនុវត្តតាម



Scanned by CamScanner

វិធានការញុះញង់លេខ ២០ អ.យ.ណ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] កំពុងធ្វើសកម្មភាពដោះដូរថ្នាំញៀនចំនួន ០១កញ្ចប់ ទម្ងន់ ៤,០៦ ក្រាម ជាមួយកម្លាំងសម្ងាត់ នៅចំណុចគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ សមត្ថកិច្ចក៏បានឃាត់ខ្លួនបានជនជាប់ចោទ រួមទាំងវត្ថុតាងថ្នាំញៀនតែម្តង ។ ដោយថ្នាំញៀនខាងលើនេះឈ្មោះ [redacted] និងម្នាក់ទៀតមិនស្គាល់ឈ្មោះ បានប្រគល់ឱ្យឈ្មោ[redacted]យកទៅលក់បន្ត ។

-បានឃើញ របាយការណ៍លេខ ០៦៥ រ.ប.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋាននគរបាលជាតិ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤២៦ អ.យ.ន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ១៥៤៨ អ.យ.ន ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៩៩៩ ដ.ដ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនមានអាយុ១៥ ឆ្នាំ កើតនៅឆ្នាំ២០០២ មុខរបរសិស្សថ្នាក់ទី៦ សមត្ថកិច្ចឃាត់ខ្លួនច្រឡំនៅពេលនោះខ្លួនកំពុងអង្គុយហូបស្ករគ្រាប់មុខផ្ទះគេនៅគល់ស្ពានស្ទឹងមានជ័យនៅម៉ោង១ជាងថ្ងៃត្រូវសមត្ថកិច្ចឃាត់ខ្លួនហើយបានដកហូតស្ករគ្រាប់ ខ្លួនទិញស្ករនោះពីផ្ទះអ្នកលក់ចាប់ហួយ ស្ក៥គ្រាប់ ០៥កញ្ចប់ ។ នៅសមត្ថកិច្ចបង្ខំខ្លួនឱ្យផ្តិតមេដៃ ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀន ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដែលបានឆ្លើយនៅអយ្យការ និងចៅក្រមស៊ើបសួរ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបន្តទៀតថា៖ ខ្លួនមិនទទួលស្គាល់ចម្លើយដែលឆ្លើយនៅតុលាការទេ ។ ខ្លួនពុំបានជួញដូរថ្នាំញៀនទេ ចំពោះឈ្មោះ [redacted] មិនមែនជាអ្នកយកថ្នាំញៀនឱ្យខ្លួនទេ ។ ខ្លួនពុំស្គាល់ឈ្មោះ[redacted]ទ ។

-ក្រឡាបញ្ជីបានអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៩១៧២/១៧ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ។

<u>-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា:</u>

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ នាពេលសវនាការរួចមក ឃើញថាកន្លងមកជន



Scanned by CamScanner

ជាប់ចោទបានឆ្លើយសារភាពរួចហើយ នាពេលសវនាការ ជនជាប់ចោទឆ្លើយដោះសារតែពុំមានភស្តុតាងដោះបន្ទុក តំណាងអយ្យការនៅតែតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរ ទុកនៅដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសម្តីចុងក្រោយថា សូមឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

<u>-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន</u>

លោក [redacted] ជាមេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖កូនក្តីខ្លួនពុំបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនទេ ។ ផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀន ឃើញថា ពុំមានផ្ទុកនូវសារធាតុញៀន ឬ សារធាតុគីមីផ្សំទេ ។ កូនក្តីខ្លួនគ្រាន់តែការសង្ស័យប៉ុណ្ណោះ ហើយកូនក្តីខ្លួនជាអនីតិជន ការឃុំខ្លួនហួសរយៈពេល ។ សំណូមពរសូមឱ្យតុលាការដោះលែងកូនក្តីខ្លួនបានត្រឡប់ទៅផ្ទះវិញ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ។

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាងនានា។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>សំអាងហេតុ</u>

១-តាមចម្លើយជនជាប់ចោទបានឆ្លើយហើយថា ខ្លួនពុំបានជួញដូរថ្នាំញៀនទេ ហើយជនជាប់ចោទបានមិនសេធចម្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរ ជាឆ្លើយដោះបន្ទុក គ្មានភស្តុតាង ដែលអាចឱ្យតុលាការជឿជាក់បានឡើយ ។

២-កាលពីថ្ងៃ១៩ ខែមករា ឆ្នាំ២០១៧ នៅចំណុចគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានកើតឡើងនូវករណីអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើងបានបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៥ ឆ្នាំ ពិតប្រាកដមែន ។ ទង្វើបែបនេះជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៩៩៩ "អ" ដ.អ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៥ ឆ្នាំ ទៅជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned by CamScanner

៤-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៥ ឆ្នាំ ជាអនីតិជនមានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវរាល់សកម្មភាពរបស់ខ្លួនចំពោះមុខច្បាប់ ដោយទង្វើរបស់ជនជាប់ចោទបានប្រព្រឹត្តប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈដែលច្បាប់បានការពារ និងបំពានលើមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៥-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៥ ឆ្នាំ ជាកំណត់អាយុដែលអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូចនេះជននេះប្រាកដជាយល់ដឹងថា អំពើរបស់ខ្លួនពិតជា ប៉ះពាល់ដល់របៀបរៀបរយសណ្ដាប់ធ្នាប់សាធារណៈ ដូច្នេះជនជាប់ចោទរូបនេះត្រូវទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន ។

៦-ផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៩១៧២/១៧ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថា សំណាកជាប្រភេទម្ស៉ៅស្ដិត ពណ៌ស ទម្ងន់ ៤,០៦ ក្រាម ពុំមានផ្ទុកនូវសារធាតុញៀន ឬសារធាតុគីមីផ្សំទេ។ ទោះបីលទ្ធផលកោសល្យវិច័យពុំមានវត្ថុមានសារធាតុញៀនក៏ពិតមែនតែជនជាប់ចោទមានចេតនាទុច្ចរិតក្នុងអំពើជួញដូរថ្នាំញៀនយ៉ាងពិតប្រាកដរហូតដល់សមត្ថកិច្ចចាប់ឃាត់បានទាន់ពេលវេលា ។

៧-វត្ថុចាប់យករួមមាន៖

-ស្រោមសំបុត្រពណ៌គគីបិទជិតចំនួន០១ មានផ្តិតមេដៃឈ្មោះ [redacted] និងមានចុះហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌ផង នៅលើស្រោមសំបុត្រសរសេរថា ក្រាមពណ៌សថ្លា ទំងន់ ៤,០៦ ( បួនក្បៀសសូន្យប្រាំមួយ ) ក្រាម ។

វត្ថុចាប់យកខាងលើនេះ គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៩៣ ,៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការបានបញ្ជាក់ពីភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទដោយតំកល់បទចោទប្រកាន់ទុកជាបានការពេញទាំងមូល និង សុំឱ្យតុលាការពិចារណា សម្រេចផ្ដន្ទាទោសទៅអំពើប្រព្រឹត្តជនជាប់ចោទ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណា និងសម្រេច ។

៩-សេចក្តីសន្និដ្ឋានរបស់មេធាវីដែលបានសន្និដ្ឋានថា កូនក្តីខ្លួនពុំបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនទេ ។ ផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀន ឃើញថា ពុំមានផ្ទុកនូវសារធាតុញៀន ឬសារធាតុគីមីផ្សំទេ ។ កូនក្តីខ្លួនគ្រាន់តែការសង្ស័យប៉ុណ្ណោះ ហើយកូនក្តីខ្លួនជាអនីតិជន ការឃុំខ្លួនហួសរយៈពេល ។ សំណូមពរសូមឱ្យតុលាការដោះលែងកូនក្តីខ្លួនបានត្រឡប់ទៅផ្ទះវិញ ជាសេចក្តីសន្និដ្ឋានសមហេតុផល ប៉ុន្តែការស្នើសុំដោះលែងកូនក្តីខ្លួននោះគឺតុលាការពុំអាចសម្រេចតាមការស្នើសុំបានឡើយ ដោយហេតុថាជនជាប់ចោទពិតជាមានចេតនាជួញដូរថ្នាំញៀនពិតប្រាកដមែន ។



Scanned by CamScanner

១០-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ[redacted]ទប្រុស អាយុ១៥ ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-សំដីចុងក្រោយរបស់ជនជាប់ចោទ គប្បីតុលាការពិនិត្យ និងពិចារណា ។

<u>**ហេតុដូច្នេះសម្រេច**</u>

១-ផ្តន្ទាទោសលើឈ្មោះ[redacted]ហៅ[redacted]ភេទប្រុស អាយុ១៥ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន ) រៀល ដើម្បីបង់ចូលជាថវិការដ្ឋ ។

**ពីបទ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅគល់ស្ពានស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២-វត្ថុចាប់យក៖**

-ស្រោមសំបុត្រពណ៌គគីបិទជិតចំនួន០១ មានផ្តិតមេដៃឈ្មោះ[redacted]និងមានចុះហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌ផង នៅលើស្រោមសំបុត្រសរសេរថា ក្រាមពណ៌សថ្លា ទំងន់ ៤,០៦ ( បួនក្បៀសសូន្យប្រាំមួយ ) ក្រាម វត្ថុចាប់យកនេះរឹបអូសតាមមាត្រា ៩៣ ,៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

“បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម”
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧
ក្រឡាបញ្ជី
[redacted]



Scanned by CamScanner